ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អ្នកនាំពាក្យ គ.ជ.ប
លេខ: ០០៤ គ.ជ.ប

ថ្ងៃ ចន្ទ ៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំផ្សព្វផ្សាយលើកទី៣ ជាមួយភាគីពាក់ព័ន្ធតាមប្រព័ន្ធវីដេអូ នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

នៅព្រឹកថ្ងៃចន្ទ ទី១១ ខែតុលា ឆ្នាំ២០២១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធតាមប្រព័ន្ធវីដេអូអនឡាញ ក្រោមអធិបតីភាព **ឯកឧត្តម មាន សទិ** សមាជិក គ.ជ.ប ដើម្បីធ្វើការផ្សព្វផ្សាយអំពីការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ នីតិវិធីចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ ការបញ្ជូនទិន្នន័យមក គ.ជ.ប និងលទ្ធផលបណ្តោះអាសន្ននៃការចែកលិខិតអញ្ជើញអ្នកចុះឈ្មោះបោះឆ្នោត។

នៅក្នុងកិច្ចប្រជុំនោះ **ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ** បានមានប្រសាសន៍ថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត មានរយៈពេល ៥០ថ្ងៃ គឺចាប់ពីថ្ងៃទី១២ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។

**ឯកឧត្តម** បានបន្តថា ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ គឺអ្នកកើតមុន ឬត្រឹមថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៤ ដែលមិនទាន់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ អាចទៅស្នើសុំចុះឈ្មោះបោះឆ្នោតដោយផ្ទាល់ជាមួយក្រុមចុះឈ្មោះបោះឆ្នោតបាន។

ចំពោះការបញ្ជូនទិន្នន័យនៃការចុះឈ្មោះបោះឆ្នោត ក្រុមចុះឈ្មោះបោះឆ្នោតត្រូវបញ្ជូនតាមអ៊ីនធឺណែត មក គ.ជ.ប ជារៀងរាល់ថ្ងៃ ដើម្បី គ.ជ.ប ធ្វើការត្រួតពិនិត្យការងារជាប្រចាំ។

ឯកឧត្តម **មាន សទិ** ក៏បានមានប្រសាសន៍អំពីលទ្ធផលនៃការចែកលិខិតអញ្ជើញអ្នកចុះឈ្មោះបោះឆ្នោតគិតត្រឹមថ្ងៃទី១១ ខែតុលាឆ្នាំ២០២១ ចែកបានចំនួន ៧.៩១៦.៧៥៥ ស្មើ ៨៩.៦៤%។ ហើយលិខិតអញ្ជើញនេះ នឹងរក្សាទុកនៅសាលាឃុំ សង្កាត់ដែលប្រជាពលរដ្ឋកំពុងរស់នៅ ដើម្បីបន្តចែកជូនអ្នកចុះឈ្មោះបោះឆ្នោតដែលមិនទាន់បានទទួល។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

ក្នុងកិច្ចប្រជុំនោះ គ.ជ.ប បានបំភ្លឺទៅនឹងការលើកឡើងរបស់ភាគីពាក់ព័ន្ធ ដែលបានចូលរួម មានដូចតទៅ ៖

- ករណីកូវីដ-១៩ ជាបញ្ហាប្រឈមក្នុងការចុះឈ្មោះបោះឆ្នោត ប៉ុន្តែ គ.ជ.ប មានវិធានការការពាររួចហើយ ហើយ គ.ជ.ប សូមថ្លែងអំណរគុណដល់អាជ្ញាធរដែនដី ដែលបានជួយឧបត្ថម្ភសម្ភារការពារជំងឺកូវីដ-១៩។
- ការិយាល័យចុះឈ្មោះបោះឆ្នោតបានបង្កើតថែមសម្រាប់ឃុំ សង្កាត់ដែលទើបបង្កើតថ្មីចំនួន ៦ ដោយផ្អែកលើចំនួនប្រជាពលរដ្ឋ។
- ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតក្រោយឆ្នាំ២០១៦ ឈ្មោះរបស់គាត់ប្រាកដជាមានក្នុងបញ្ជីបោះឆ្នោត ដើម្បីឱ្យជាក់ច្បាស់សូមឆែកមើលក្នុងគេហទំព័រ voterlist.nec.gov.kh ឬតាម App-Voterlist KH ។ ម្យ៉ាងទៀតប្រសិនបើគាត់ទទួលបានលិខិតអញ្ជើញអ្នកចុះឈ្មោះបោះឆ្នោត ក៏ប្រាកដថាគាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយដែរ។
- គ.ជ.ប បានផលិតកម្មវិធីផ្សព្វផ្សាយជាច្រើនតាមវិទ្យុ ទូរទស្សន៍ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបំផុសឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានអំពីការចុះឈ្មោះបោះឆ្នោត។ ជាពិសេសមានការចូលរួមជួយផ្សព្វផ្សាយដោយភាគីពាក់ព័ន្ធទាំងអស់ រួមទាំងមេភូមិ និងស្មារតីចូលរួមរបស់ប្រជាពលរដ្ឋផងដែរ។
- ក្នុងករណីប្រជាពលរដ្ឋផ្លាស់ប្តូរទីលំនៅ ហើយចង់បោះឆ្នោតនៅក្នុងឃុំ សង្កាត់ដែលគាត់កំពុងរស់នៅ គាត់ត្រូវតែបំពេញលក្ខខណ្ឌ ដើម្បីសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ។

មុននឹងបញ្ចប់កិច្ចប្រជុំ ឯកឧត្តម **មាន សទិ** បានសំណូមពរដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋអ្នកចុះឈ្មោះបោះឆ្នោត និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាអនាម័យផ្ទាល់ខ្លួន ដោយអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល និង គ.ជ.ប ដែលបានដាក់ចេញ ឱ្យបានខ្ជាប់ខ្ជួន ដើម្បីបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ភាគីពាក់ព័ន្ធដែលបានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ មានតំណាងក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា រដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន មន្ត្រីស្ថានទូតជប៉ុន តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អង្គភាពសារព័ត៌មាន និងមន្ត្រី គ.ជ.ប សរុបអ្នកចូលរួមមានចំនួនប្រមាណ ៧៥នាក់៕

x



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh